| ៦៥ | ភួង ខេង | ប្រុស | ៤៣ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៦៦ | នៅ ផុន | ប្រុស | ៤៩ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៦៧ | លឹម លាង | ប្រុស | ៥៤ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៦៨ | មួង អេងងួន | ស្រី | ៤៩ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៦៩ | នៅ សៀម | ប្រុស | ៤៦ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧០ | សេង ស្រេង | ប្រុស | ៣៦ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧១ | ឌុច យ៉ាន | ប្រុស | ២១ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧២ | ឡាច វ៉ន | ប្រុស | ៥៧ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៣ | សែម ភិន | ប្រុស | ៤៨ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៤ | រស់វ៉ា | ប្រុស | ២០ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៥ | ម៉ម ស្រី | ប្រុស | ១៩ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៦ | សុង សីហា | ប្រុស | ៤៣ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៧ | សាយ អឿន | ប្រុស | ៤៩ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៨ | រឿន សឿន | ស្រី | ៣៦ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៧៩ | ម៉ុក លីម | ប្រុស | ២១ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៨០ | ក វ៉ាង | ប្រុស | ៥៧ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៨១ | សៀង ហៃ | ប្រុស | ៤៨ | ខ្មែរ | មេសរ | នេសាទ | ១៥ / ៥ / ២០០៧ |
| ៨២ | ទូ ឌុ | ប្រុស | ៣៤ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៣ | ផន សម្ផស្ស | ប្រុស | ២៧ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៤ | ឈិន សុជាតិ | ប្រុស | ៣២ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៥ | សុខ ស៊ីថា | ប្រុស | ៤៩ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៦ | ម៉ែន សំ | ប្រុស | ៤៩ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៧ | ម៉ែត គីមសេង | ស្រី | ៣៥ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ៨៨ | យុន វ៉ានី | ប្រុស | ៣៤ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៨៩ | តឹង ហន | ប្រុស | ៣៨ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៩០ | អ៊ូ ស៊ុនីន | ប្រុស | ៤១ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៩១ | ឆេង វ៉ាន់ឌី | ប្រុស | ៤០ | ខ្មែរ | គងជ័យ | នេសាទ | ១៦ / ៥ / ២០០៧ |
| ៩២ | សាន វ៉ាន | ប្រុស | ៣៤ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៣ | ឈុន ហុង | ប្រុស | ៤៥ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៤ | ឆុន ស្រីពៅ | ស្រី | ២៤ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៥ | ឥត ពៅ | ប្រុស | ៣៥ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៦ | យ៉ន ថា | ប្រុស | ៣៧ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៧ | នាង ឃ្លី | ប្រុស | ៤១ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៨ | វិត មំ | ស្រី | ៣២ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ៩៩ | សយ ម៉ៅ | ប្រុស | ៣៧ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០០ | រស់ ហឿង | ប្រុស | ៣៤ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០១ | សេង ផានី | ប្រុស | ៤១ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០២ | គង់ សឿន | ស្រី | ២៨ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៣ | អៀ ប៊ុនសុង | ប្រុស | ៣៥ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៤ | ហៀង ហូ | ប្រុស | ៣០ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៥ | សេក ភួម | ស្រី | ៣១ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៦ | ធី គីមអេង | ប្រុស | ៤៣ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៧ | សន កក្កដា | ប្រុស | ៣២ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៨ | នុល ឆេងហ៊ាង | ប្រុស | ៤២ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១០៩ | ឈុន ហៃ | ប្រុស | ៤២ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១០ | ហេង គីមអ៊ាង | ប្រុស | ៤៨ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១១ | ហុង ហេង | ប្រុស | ៣៥ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១២ | ធុន ហួត | ប្រុស | ៤២ | ខ្មែរ | គោហ៊ើ | នេសាទ | ១៧ / ៥ / ២០០៧ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| ១១៣ | ផូ ថូ | ប្រុស | ៤០ | ខ្មែរ | គោហ៊ៃ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១៤ | នុន នុល | ប្រុស | ៣៧ | ខ្មែរ | គោហ៊ៃ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១៥ | ហេង ហន | ប្រុស | ៤១ | ខ្មែរ | គោហ៊ៃ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១៦ | សន អូន | ប្រុស | ៤៥ | ខ្មែរ | គោហ៊ៃ | នេសាទ | ១៧ / ៥ / ២០០៧ |
| ១១៧ | ណិត ណន | ប្រុស | ៤៨ | ខ្មែរ | គោហ៊ៃ | នេសាទ | ១៧ / ៥ / ២០០៧ |

ធ្វើថ្ងៃទី....05.......ខែ...01.......ឆ្នាំ២០០៨

**ប្រធានគណៈកម្មការសហពន្ធ័សហគមន៍**

**នេសាទបឹងជ្រាំងខ្ពុម**

ចាន់ ស្មៀន

បានឃើញ និងឯកភាព

ថ្ងៃទី...06....ខែ.....01........ឆ្នាំ២០០៨

**មេឃុំច្បារអំពៅ**

ពៅ សារឿន

បានឃើញ និងឯកភាព

ថ្ងៃទី...06...ខែ.....01.......ឆ្នាំ២០០៨

**មេឃុំតាំងក្រាំង**

ក្រូច សាន

បានឃើញ និងឯកភាព

ថ្ងៃទី....06..ខែ.....01.........ឆ្នាំ២០០៨

**មេឃុំខ្វាលា**

ឈិត សុខឿន

បានឃើញ និងឯកភាព

ថ្ងៃទី.......06 ខែ......01........ឆ្នាំ២០០៨

**មេឃុំជ្រៃព្រាក្រុយ**

សោម គី

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លក្ខន្តិកៈសហគមន៍នេសាទ

ឈ្មោះសហគមន៍នេសាទ : ប្រាំងខ្ទុម

ភូមិ : ច្បារអំពៅ ទួលចាន់ ស្ទឹងឆ្វេង តាងិល តាំងក្រាំង កំពង់ព្រះ មេសរ គោហើ គងជ័យ

ឃុំ : ច្បារអំពៅ ជាលា តាំងក្រាំង ព្រែកកុយ

ស្រុក : បាធាយ កងមាស

ខេត្ត : កំពង់ចាម

## ជំពូកទី ១
## គោលបំណង និងនាមករណ៍

**ប្រការ ១ :**

លក្ខន្តិកៈនេះមានគោលបំណង :

-កំណត់ក្របខ័ណ្ឌនៃការគ្រប់គ្រង ការការពារ ការអភិរក្ស ការអភិវឌ្ឍន៍ និងការប្រើប្រាស់ធនធានជលផល របស់សហគមន៍នេសាទប្រកបដោយនិរន្តរភាព ។

-ធ្វើជាគោលការណ៍គ្រឹះ និងជាយន្តការសម្រាប់ដំណើរការសហគមន៍នេសាទ

-ការពារសិទ្ធិ និងផលប្រយោជន៍សមាជិកសហគមន៍នេសាទ និងផលប្រយោជន៍សាធារណៈ ។

**ប្រការ ២ :**

ឈ្មោះសហគមន៍នេសាទ **ប្រាំខ្ទម** ហៅកាត់ថា ស.ន.ប.ខ អាស័យដ្ឋាន ផ្ទះលេខ.....ភូមិតាងិល ឃុំជាលា ស្រុកបាធាយ ខេត្តកំពង់ចាម ។

សហគមន៍នេសាទនេះមានការចូលរួមពីប្រជាពលរដ្ឋដែលរស់ក្នុង ÷

១-ភូមិតាងិល និង ភូមិតាំងក្រាំង ឃុំជាលា ស្រុកបាធាយ

២-ភូមិកំពង់ព្រះ ឃុំតាំងក្រាំង ស្រុកបាធាយ

៣-ភូមិច្បារអំពៅ ភូមិទូលចាន់ ភូមិអន្លង់ជ្រៃ និងភូមិស្ទឹងឆ្វេង ឃុំច្បារអំពៅ ស្រុកបាធាយ

៤-ភូមិមេសរ ភូមិគោហ៊ៃ និងភូមិគងជ័យ ឃុំព្រែកកុយ ស្រុកកងមាស

**មានកម្មវត្ថុ** :ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផល និបរិស្ថានឱ្យមាននិរន្តរភាព ។

## ជំពូកទី ២
## លក្ខខណ្ឌនៃការសុំចូលជាសមាជិក ភារកិច្ច និងសិទ្ធិរបស់សមាជិក

**ប្រការ ៣ :**

ប្រជាពលរដ្ឋទាំងពីរភេទ ដែលមានបំណងចង់ចូលជាសមាជិកសហគមន៍ មានសិទ្ធិដាក់ពាក្យសុំចូលដោយស្ម័គ្រចិត្ត និងត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម ÷

-មានលំនៅដ្ឋាននៅក្នុងបណ្ដាភូមិនៃសហគមន៍នេសាទ

-មានសញ្ជាតិខ្មែរ

-មានអាយុ ១៨ឆ្នាំឡើង

**ប្រការ ៤ :**

សមាជិកសហគមន៍នេសាទដែលបានបំពេញលក្ខខណ្ឌក្នុងប្រការ ៣ ខាងលើមានសិទ្ធិ ÷

-ចូលរួមប្រជុំមហាសន្និបាត និងបោះឆ្នោតស្មើភាពគ្នា

-បោះឆ្នោត និងឈរឈ្មោះជាបេក្ខជន នៃគណៈកម្មការសហគមន៍នេសាទ ស្របតាមលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ

-ទទួលពត៌មានអំពីស្ថានភាពសេដ្ឋកិច្ចសង្គមរបស់សហគមន៍នេសាទពីគណៈកម្មការសហគមន៍នេសាទ

-ស្នើឱ្យមានការកោះប្រជុំមហាសន្និបាតវិសាមញ្ញ ដើម្បីធ្វើការពិភាក្សា និងសម្រេចលើបញ្ហាណាមួយបើមានការស្នើសុំពីសមាជិកយ៉ាងតិច មួយភាគបី ( ១/៣) នៃសមាជិកសហគមន៍នេសាទទាំងអស់

-ធ្វើនេសាទជាលក្ខណៈគ្រួសារ ស្របតាមច្បាប់ជលផល កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ និងលិខិតបទដ្ឋានគតិយុត្តិនានា ដែលពាក់ព័ន្ធវិស័យជលផល

-ចូលរួមក្នុងសកម្មភាពទាំងអស់របស់សហគមន៍នេសាទ

-ប្តឹងតវ៉ា ឬផ្តល់ព័ត៌មានអំពីបាតុភាពទាំងឡាយ ដែលប៉ះពាល់ដល់ផលប្រយោជន៍របស់សហគមន៍ ទៅសមត្ថកិច្ចជលផលក្រុមប្រឹក្សាឃុំ អាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ព័ន្ធ ។

-ទទួលបានការគាំទ្រពីមជ្ឈដ្ឋាននានា ដើម្បីផលប្រយោជន៍សហគមន៍ ។

សមាជិកសហគមន៍នេសាទត្រូវ ទទួលខុសត្រូវរាល់សកម្មភាពរៀង១ ខ្លួន និងរួមគ្នាផង ចំពោះកំហុសដែលខ្លួនបានប្រព្រឹត្ត ក្នុងពេលបំពេញភារកិច្ចដោយមិនទាន់គិតដល់ការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌឡើយ ។

សមាជិកសហគមន៍នេសាទចំនួនមួយភាគដប់ (១/១០)ឡើងទៅ អាចស្នើសុំឱ្យប្រធានគណៈកម្មការសហគមន៍នេសាទបញ្ចូលបញ្ហាមួយចំនួនទៅរបៀបវារៈ នៃកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទសាមី ហើយចំនួនសមាជិកសហគមន៍នេសាទដែលបានស្នើសុំខាងលើនេះ អាចចាត់តំណាងចំនួនបី (៣)នាក់ ចូលរួមប្រជុំ ដើម្បីចោទសួរគណៈកម្មការសហគមន៍នេសាទនូវបញ្ហាទាំងឡាយដែលទាក់ទងចំណុចដែលបានស្នើឡើងនោះ ។

**ប្រការ ៥ :**

សមាជិកសហគមន៍នេសាទមានកាតព្វកិច្ច និងភារៈកិច្ចដូចខាងក្រោម :

-អនុវត្តន៍តាមបទប្បញ្ញត្តិនៃច្បាប់ស្តីពីជលផល

-អនុវត្តន៍តាមព្រះរាជក្រឹត្យលេខ នស / រកត /០៥០៥/២៤០ ចុះថ្ងៃទី ២៩ ខែ ឧសភា ឆ្នាំ ២០០៥ ស្តីពីការបង្កើតសហគមន៍នេសាទ ។

-អនុវត្តន៍តាមអនុក្រឹត្យលេខ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ និងលិខិតបទដ្ឋានផ្សេងៗ ទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

-អនុវត្តន៍តាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀង និង ផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

-អនុវត្តន៍តាមសេចក្តីសម្រេចរបស់មហាសន្និបាត និងគណៈកម្មការសហគមន៍នេសាទ

-បង់ប្រាក់សមាជិកភាពចំនួន **៥០០រៀល** ពេលដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

-បង់ប្រាក់វិភាគទានប្រចាំឆ្នាំ ចំនួន **៥.០០០ រៀល**

-ចូលរួមក្នុងសកម្មភាពរបស់សហគមន៍នេសាទ ដើម្បីផលប្រយោជន៍និងការរីកចំរើនរបស់សហគមន៍នេសាទ ។

-ចូលរួមការពារ ថែរក្សា និងគ្រប់គ្រងធនធានជលផលក្នុងសហគមន៍នេសាទ

-ចូលរួមឃ្លាំមើល ទប់ស្កាត់ និងរាយការណ៍រាល់សកម្មភាពបទល្មើសជលផលក្នុងកន្លែងនេសាទសហគមន៍ ។ .

## ជំពូកទី ៣
## លក្ខណៈវិនិច្ឆ័យ លក្ខខណ្ឌនៃការលាឈប់ និងការបណ្តេញចេញពីសមាជិក

**ប្រការ ៦ :**

សមាជិកសហគមន៍នេសាទមានសិទ្ធិលាឈប់ពីសមាជិកភាពបានដោយ :

-ដាក់ពាក្យសុំលាលែងជាលាយលក្ខណ៍អក្សរ

-ការផ្លាស់ប្តូរទីលំនៅដ្ឋានចេញពីកន្លែងនេសាទសហគមន៍

-សាមីខ្លួនទទួលមរណភាព

-សាមីខ្លួនបាត់បង់សម្បទាវិជ្ជាជីវៈ ដោយមាន លិខិតបញ្ជាក់ពីស្ថាប័នមានសមត្ថកិច្ច ។

**ប្រការ ៧ :**

សមាជិកសហគមន៍អាចត្រូវបណ្តេញចេញពីសមាជិកភាពក្នុងលក្ខខណ្ឌដូចខាងក្រោម :

-ការមិនបង់វិភាគទានចំនួន ៣ឆ្នាំជាប់ៗ គ្នា

-ការធ្វើអោយប៉ះពាល់ខ្លាំងដល់ផលប្រយោជន៍សហគមន៍នេសាទដទៃទៀត

-សាមីខ្លួនត្រូវតុលាការផ្តន្ទាទោសដាក់ពន្ធនាគារពីបទឧក្រិដ្ឋ ឬ បទមជ្ឈិម

-សាមីខ្លួនបានប្រព្រឹត្តផ្ទុយនឹងលក្ខន្តិកៈ ឬ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ

## ជំពូកទី ៤
## របៀបកាន់បញ្ជី និងឯកសារនានា

**ប្រការ ៨ :**

ប្រភពហិរញ្ញវត្ថុរបស់សហគមន៍នេសាទបានមកពី :

-ភាគទានរបស់សមាជិកសហគមន៍នេសាទ

-អំណោយពីសប្បុរសជន

-ជំនួយពីរាជរដ្ឋាភិបាល អង្គការជាតិ និងអង្គការមិនមែនរដ្ឋាភិបាល

-ចំណូលស្របច្បាប់ផ្សេងៗទៀត ។

**ប្រការ ៩ :**

រាល់ការចំណាយថវិកាសហគមន៍ត្រូវអនុវត្តដូចតទៅ :

-ការចំណាយពី **៥០.០០០រៀល** ចុះ ត្រូវសម្រេចដោយប្រធានគណៈកម្មការសហគមន៍នេសាទ

-ការចំណាយពី **៥០.០០០រៀល** ដល់ **២០០.០០០រៀល**ត្រូវសម្រេចដោយគណៈកម្មការសហគមន៍

-ការចំណាយពី **២០០.០០០រៀល** ឡើងទៅ ត្រូវសម្រេចដោយមហាសន្និបាត។

**ប្រការ ១០ :**

សហគមន៍នេសាទត្រូវតម្កល់ទុកឯកសារ និងរៀបចំអោយមានបញ្ជីរាល់សកម្មភាពរបស់ខ្លួន :

-ចំណូល ចំណាយថវិកា

-សារពើភ័ណ្ឌ

-សមាជិកសហគមន៍នេសាទ

-កំណត់ហេតុប្រជុំមហាសន្និបាតសហគមន៍នេសាទ

-កំណត់ហេតុប្រជុំគណៈកម្មការសហគមន៍នេសាទ

-ឯកសារដទៃទៀតដែលពាក់ព័ន្ធនឹងសហគមន៍នេសាទ ។

**ប្រការ ១១ :**

ការគ្រប់គ្រង និងការប្រើប្រាស់ថវិកា :

-ការគ្រប់គ្រងថវិកា ត្រូវអនុវត្តតាមប្រព័ន្ធការងារគណនេយ្យ

-ថវិកាចំណូលដែលទទួលបានពីប្រភពផ្សេងៗ ត្រូវរក្សាទុកក្នុងបេឡារបស់សហគមន៍នេសាទ

-រាល់ថវិកាចំណាយ ត្រូវមានវិក័យប័ត្រ និងបញ្ជីត្រឹមត្រូវ

-ថវិកាដែលត្រូវចំណាយ គឺសម្រាប់តែបំរើអោយការងារគ្រប់គ្រង អភិរក្ស និងអភិវឌ្ឍន៍សហគមន៍នេសាទ ។

## ជំពូកទី ៥

## គណៈកម្មការសហគមន៍នេសាទ

### ប្រការ ១២ :

សមាសភាពគណៈកម្មការសហគមន៍នេសាទរួមមាន ប្រធាន អនុប្រធាន និងសមាជិក ។ គណៈកម្មការសហគមន៍នេសាទត្រូវបោះឆ្នោតជ្រើសរើសសមាជិកទទួលបន្ទុកលេខាធិការ ០១រូប និងសមាជិកទទួលបន្ទុក ហិរញ្ញិក ០១រូប និងត្រូវពិភាក្សាបែងចែកភារកិច្ចសមាជិកផ្សេងទៀតតាមការជាក់ស្តែង ។

ប្រធានគណៈកម្មការសហគមន៍នេសាទទទួលខុសត្រូវដឹកនាំ និងគ្រប់គ្រងសហគមន៍នេសាទទាំងមូល ។ អនុប្រធាន គណៈកម្មការសហគមន៍នេសាទជាជំនួយការឱ្យប្រធាន ។

### ប្រការ ១៣ :

គណៈកម្មការសហគមន៍នេសាទមានអាណត្តិប្រាំ (៥) ឆ្នាំ ចាប់ពីថ្ងៃបោះឆ្នោត ហើយផុតកំណត់នៅពេលដែលមានគណៈកម្មការសហគមន៍នេសាទថ្មី ដែលត្រូវបានបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាត ឱ្យចូលកាន់តំណែងជំនួស ។ ក្នុងករណីសហគមន៍នេសាទដំណើរការមិនប្រក្រតី ដោយមូលហេតុមិនល្អ ឬ អសមត្ថភាពក្នុងការគ្រប់គ្រងសហគមន៍នេសាទ សមាជិកសហគមន៍ចំនួនមួយភាគបី (១/៣) មានសិទ្ធិស្នើសុំបើកមហាសន្និបាតវិសាមញ្ញ ដើម្បីបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទជាថ្មី ។

### ប្រការ ១៤ :

ក្នុងករណីដែលសមាជិកគណៈកម្មការសហគមន៍នេសាទណាមួយអវត្តមាន ដោយគ្មានមូលហេតុ រយៈពេលប្រាំមួយ(៦)ខែ ឬសុំលាលែងមុនចប់អាណត្តិបេក្ខជនដែលមានឈ្មោះតាមសំលេងគាំទ្របន្ទាប់ក្នុងពេលបោះឆ្នោតជ្រើសរើសក្នុងមហាសន្និបាតកន្លងមក ត្រូវបានជ្រើសតាំងជំនួស ។

## ជំពូកទី ៦

## របៀបរបបប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៥ :**

គណៈកម្មការសហគមន៍នេសាទ ត្រូវធ្វើការប្រជុំឱ្យបានទៀងទាត់រៀងរាល់ខែ ។ កិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទអាចប្រព្រឹត្តទៅបាន លុះត្រាមានសមាជិកគណៈកម្មការចូលរួមយ៉ាងតិចចំនួន ២/៣ ( ពីរភាគបី ) នៃសមាជិកគណៈកម្មការសហគមន៍នេសាទទាំងមូល ។

**ប្រការ ១៦ :**

ប្រធានគណៈកម្មការសហគមន៍នេសាទ ជាអ្នកកោះអញ្ជើញ និងធ្វើជាប្រធានគ្រប់កិច្ចប្រជុំ ។ ក្នុងករណីប្រធានគណៈកម្មការសហគមន៍នេសាទអនុវត្តមាន អនុប្រធានដែលត្រូវបានការប្រគល់សិទ្ធិ ត្រូវធ្វើការ ជាប្រធានអង្គប្រជុំ ។ រាល់ការប្រជុំត្រូវមានកំណត់ហេតុ និងបញ្ជីវត្តមានច្បាស់លាស់ ។

ប្រធានអង្គប្រជុំត្រូវធានាឱ្យគ្រប់កិច្ចប្រជុំសហគមន៍នេសាទប្រព្រឹត្តទៅដោយមានលក្ខណៈប្រជាធិបតេយ្យមានរបៀបរៀបរយ និងគ្មានការរំខាន ។

ប្រធានអង្គប្រជុំអាចបណ្តេញសមាជិកអង្គប្រជុំណាម្នាក់ចេញពីកិច្ចប្រជុំបាន ក្នុងករណីដែលសមាជិកនោះ ធ្វើឱ្យខូចសណ្តាប់ធ្នាប់អង្គប្រជុំ ។

**ប្រការ ១៧ :**

ការសម្រេចលើបញ្ហាណាមួយរបស់សហគមន៍ដូចមានចែងខាងក្រោមនេះ គឺ ត្រូវអនុម័តដោយកិច្ចប្រជុំរបស់គណៈកម្មការសហគមន៍នេសាទ ដោយមានសម្លេងគាំទ្រយ៉ាងតិចលើសពីពាក់កណ្តាលនៃចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទដែលមានវត្តមានក្នុងអង្គប្រជុំ ។ ក្នុងករណីដែលមានសម្លេងស្មើគ្នា មតិប្រធាន

អង្គប្រជុំជាឧត្តមានុភាព ÷

-សេចក្តីព្រាងកិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-សេចក្តីព្រាងគម្រោងថវិកា ចំណូល និងចំណាយក្នុងសហគមន៍នេសាទ

-ការព្យួរសមាជិកភាពរបស់សមាជិកដែលមានកំហុស

-ការទទួលពាក្យសុំចូលជាសមាជិកសហគមន៍នេសាទថ្មី

-ការដាក់ទណ្ឌកម្មតាមបទបញ្ជាផ្ទៃក្នុង ដល់សមាជិកសហគមន៍នេសាទ ។

បន្ទាប់ពីកិច្ចប្រជុំភ្លាម ប្រធានគណៈកម្មការសហគមន៍នេសាទត្រូវចាត់ឱ្យធ្វើការជូនដំណឹងដល់សមាជិកសហគមន៍នេសាទអំពីសេចក្តីសំរេចរបស់ខ្លួន ។ សេចក្តីសម្រេចនៃអង្គប្រជុំរបស់គណៈកម្មការសហគមននេសាទត្រូវបិទផ្សាយ ជាសាធារណៈនៅទីស្នាក់ការសហគមន៍នេសាទ ឬសាលាឃុំ ក្នុងរយៈពេល ៧ ថ្ងៃយ៉ាងយូរបន្ទាប់ ពីការប្រជុំ ។

## ជំពូកទី ៧

## មហាសន្និបាតសហគមន៍នេសាទ

**ប្រការ ១៨ :**

មហាសន្និបាតសហគមន៍នេសាទជាអង្គការកំពូល ដើម្បីធ្វើការអនុមត័ និងធ្វើសេចក្តីសម្រេចចិត្តទាំងឡាយក្នុងនាមសហគមន៍នេសាទ ។ មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ត្រូវប្រារព្ធធ្វើឡើងបន្ទាប់ពីក្រុមស្ថាបនិកបានរៀបចំរួចរាល់នូវកិច្ចការទាំងឡាយដែលពាក់ព័ន្ធនឹងដំណើរការមហាសន្និបាត ។

ការកោះប្រជុំមហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ ធ្វើឡើងដោយក្រុមប្រឹក្សាឃុំដោយមានការជួយសម្របសម្រួលពីសមត្ថកិច្ចរដ្ឋបាលជលផលតាមការស្នើសុំរបស់ក្រុមស្ថាបនិក ហើយត្រូវមានការចូលរួមពីសមាជិកដែលបានដាក់ពាក្យសុំរួចមកហើយ ។

មហាសន្និបាតកំណើតដំបូងរបស់សហគមន៍នេសាទ អនុម័តនូវសេចក្តីសម្រេច និងកិច្ចការសំខាន់ ដូចខាងក្រោម ÷

-អ្នកដែលដាក់ពាក្យសុំចូលជាសមាជិកសហគមន៍នេសាទ

-ឈ្មោះសហគមន៍នេសាទ

-លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

-ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ១៩ :**

មហាសន្និបាតសាមញ្ញត្រូវបានរៀបចំឡើង១ឆ្នាំម្តង ដើម្បីសរុបលទ្ធផលការងារប្រចាំឆ្នាំ និងអនុម័តនូវកិច្ចការសំខាន់ៗ របស់សហគមន៍នេសាទ ។ ក្នុងករណីចាំបាច់ សហគមន៍អាចរៀបចំមហាសន្និបាតវិសាមញ្ញតាមការស្នើសុំពីសមាជិកសហគមន៍នេសាទ ចំនួនមួយភាគបី (១/៣) យ៉ាងតិច ។

**ប្រការ ២០ :**

គណៈកម្មការសហគមន៍នេសាទអាចអញ្ជើញរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ឬ ក្រុមប្រឹក្សាឃុំ សង្កាត់ សមត្ថកិច្ចពាក់ព័ន្ធ និងអ្នកគាំទ្រចូលរួមសង្កេតការណ៍ ឬ សម្របសម្រួល ឬជាកិត្តិយសក្នុងមហាសន្និបាតសហគមន៍នេសាទ

**ប្រការ ២១ :**

លក្ខខណ្ឌនៃដំណើរការបមហាសន្និបាតមានដូចខាងក្រោម :

-ត្រូវធ្វើការផ្សព្វផ្សាយសេចក្តីជូនដំណឹងជាសាធារណៈ និងបិទប្រកាសនៅសាលាឃុំ និងទីស្នាក់ការសហគមន៍នេសាទ

-ការកោះអញ្ជើញសមាជិកសហគមន៍នេសាទឱ្យចូលរួមមហាសន្និបាតសាមញ្ញត្រូវធ្វើឡើងដប់(១០)ថ្ងៃយ៉ាងតិចមុនថ្ងៃបើកមហាសន្និបាត និងបី(៣)ថ្ងៃ យ៉ាងតិចមុនថ្ងៃមហាសន្និបាតវិសាមញ្ញ

-មហាសន្និបាតសាមញ្ញ ឬ វិសាមញ្ញអាចប្រជុំពិភាក្សាអនុម័ត និងសំរេចបានលុះត្រាតែមានវត្តមាន លើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទ ។

-អង្គប្រជុំមហាសន្និបាតដឹកនាំដោយប្រធានគណៈកម្មការសហគមន៍នេសាទ ឬប្រធានអង្គប្រជុំដែលជ្រើសរើសដោយការអនុម័តក្នុងចំណោមសមាជិកវត្តមាន ។

-មហាសន្និបាតត្រូវអនុម័តលេខាកត់ត្រា ដើម្បីធ្វើកំណត់ហេតុ សេចក្តីសម្រេច និងបញ្ជីវត្តមាន

-លេខាកត់ត្រា និងប្រធានអង្គប្រជុំ ត្រូវចុះហត្ថលេខាលើកំណត់ហេតុ

-សមាជិកម្នាក់មានសំលេងតែមួយគត់ ហើយមិនអាចបញ្ជូនមនុស្សមកតំណាងបានទេ ។

-សេចក្តីសម្រេចរបស់មហាសន្និបាតត្រូវយកសំលេងលើសពីពាក់កណ្តាលនៃចំនួនសមាជិក ដែលមានវត្តមាន ។

**ប្រការ ២២ :**

មហាសន្និបាតអនុម័ត :

-សេចក្តីសម្រេចដូចមានចែងក្នុងប្រការ ១៨ កថាខណ្ឌទី៣ នៃលក្ខន្តិកៈនេះ

-កិច្ចព្រមព្រៀង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍

-តួនាទី ភារៈកិច្ច និងរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

-ការសុំលាលែង ឬ ការបណ្តេញចេញពីសមាជិកភាព ឬ សមាជិកគណៈកម្មការសហគមន៍នេសាទ

-របាយការណ៍ប្រចាំឆ្នាំរបស់គណៈកម្មការសហគមន៍នេសាទ

-គម្រោងចំណូល ចំណាយរបស់សហគមន៍នេសាទ

## ជំពូកទី ៨

## ការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ

**ប្រការ ២៣ :**

ចំនួនសមាជិកគណៈកម្មការសហគមន៍នេសាទ និងចំនួនបេក្ខជនឈរឈ្មោះ ត្រូវអនុម័តដោយមហាសន្និបាត ។

**ប្រការ ២៤ :**

កិច្ចដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ គឺជាភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតដែលអនុម័តដោយមហាសន្និបាត ។ គណៈកម្មការរៀបចំការបោះឆ្នោតមានសមាសភាព ពីបី ទៅ ប្រាំនាក់ (៣ ទៅ ៥នាក់ ) ដែលមានប្រធាន អនុប្រធាន និងសមាជិកតាមការកំណត់ជាក់ស្តែងរបស់មហាសន្និបាត និងមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ មានចំណេះដឹង និងមានសីលធម៌ល្អ ។ គណៈកម្មការរៀបចំការបោះឆ្នោត ត្រូវធ្វើការប្តេជ្ញាបង្ហាញពីភាពស្មោះត្រង់ ។

**ប្រការ ២៥ :**

គណៈកម្មការរៀបចំការបោះឆ្នោតមានភារកិច្ចដូចខាងក្រោម ÷

-ប្រកាសបេក្ខជនឈរឈ្មោះ

-ណែនាំអំពីនិតិវិធីនៃការបោះឆ្នោត

-បង្ហាញរចនាសម្ព័ន្ធរបស់គណៈកម្មការសហគមន៍នេសាទ

-រាប់សន្លឹកឆ្នោត និងសរុបលទ្ធផលជូនគណៈអធិបតី ដើម្បីប្រកាសជូនមហាសន្និបាត

-ភារកិច្ចរបស់គណៈកម្មការរៀបចំការបោះឆ្នោតត្រូវបានបញ្ចប់ដោយស្វ័យប្រវត្តិបន្ទាប់ពីបានប្រកាស លទ្ធផលបោះឆ្នោតចប់ជាស្ថាពរ ។

**ប្រការ ២៦ :**

បេក្ខជនដែលទទួលបានសំលេងឆ្នោតគាំទ្រច្រើនជាងគេបង្អស់ គឺ ជាប្រធានគណៈកម្មការសហគមន៍នេសាទ។ បេក្ខជនដែលទទួលបានសន្លឹកឆ្នោតបន្តបន្ទាប់ត្រូវទទួលនាទីជាអនុប្រធាន ជាសមាជិកគណៈកម្មការ សហគមន៍នេសាទតាមលំដាប់លំដោយ ។ ក្នុងករណីបេក្ខជនដែលមានសំលេងឆ្នោតគាំទ្រស្មើគ្នាត្រូវជ្រើសរើស ស្ត្រី ឬបោះឆ្នោតរកអ្នកដែលមានសមត្ថភាព ដោយលើកដៃយកមតិលើសពីពាក់កណ្តាលនៃចំនួនសមាជិកសហគមន៍នេសាទដែលចូលរួម ។

## ជំពូកទី ៩

## លក្ខខណ្ឌនៃការរំសាយសហគមន៍នេសាទ និងនិតិវិធីដោះស្រាយវិវាទ

**ប្រការ ២៧ :**

ការរំសាយសហគមន៍នេសាទត្រូវផ្អែកតាម ÷

-សំណើររបស់ខណ្ឌរដ្ឋបាលជលផល នៅពេលដែលពិនិត្យឃើញថា មានការរំលោភធ្ងន់ធ្ងរលើកិច្ចព្រមព្រៀង

កន្លែងនេសាទសហគមន៍

-សេចក្តីសម្រេចមហាសន្និបាតក្រោយពីរំសាយសហគមន៍នេសាទទ្រព្យសម្បត្តិសហគមន៍ត្រូវចាត់ចែងតាមការអនុម័តរបស់មហាសន្និបាតលើកលែងតែដែននេសាទត្រូវប្រគល់ជូនរដ្ឋវិញ ។

**ប្រការ ២៨ :**

ក្នុងករណីមានការតវ៉ាចោទប្រកាន់ថា ដំណើរការបោះឆ្នោតជ្រើសរើសគណៈកម្មការសហគមន៍នេសាទ មានភាពមិនប្រក្រតី អ្នកតវ៉ាត្រូវបង្ហាញភស្តុតាងឱ្យបានច្បាស់លាស់ អំពីភាពមិនប្រក្រតីនោះភ្លាម នៅមុនពេលប្រកាសលទ្ធផលបោះឆ្នោត ដើម្បីទុកលទ្ធភាពជូនមហាសន្និបាតពិនិត្យ និងសម្រេច ។

**ប្រការ ២៩ :**

វិវាទទាំងឡាយនៅក្នុងសហគមន៍នេសាទ ត្រូវដោះស្រាយដូចខាងក្រោម ÷

-គណៈកម្មការសហគមន៍នេសាទត្រូវសម្រុះសម្រួលនិងដោះស្រាយរាល់វិវាទដែលកើតឡើងនៅក្នុងសហគមន៍នេសាទរបស់ខ្លួន

-ក្នុងករណីគណៈកម្មការសហគមន៍នេសាទដោះស្រាយវិវាទនោះពុំបានសម្រេច ត្រូវបញ្ជូនសំណុំរឿងនោះទៅសមត្ថកិច្ចរដ្ឋបាលជលផល ដើម្បីដោះស្រាយទៅតាមឋានានុក្រម ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចពាក់ពន្ធ័តាមការចាំបាច់ ។

-ក្នុងករណីដែលបញ្ហាវិវាទនោះនៅតែមិនអាចដោះស្រាយបាន គណៈកម្មការសហគមន៍នេសាទ និង រដ្ឋបាលជលផលត្រូវបញ្ជូនសំណុំរឿងទៅតុលាកាខេត្ត ក្រុងសាមី ដើម្បីដោះស្រាយតាមផ្លូវច្បាប់ ។

**ប្រការ ៣១ :**

សមាជិកសហគមន៍នេសាទរូបណា ដែលមិនគោរពតាមលក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវទទួលទណ្ឌកម្ម ពីគណៈកម្មការសហគមន៍នេសាទ ឬមហាសន្និបាតសហគមន៍នេសាទទៅតាមកម្រិតនៃទោសកំហុសរបស់ខ្លួន

## ជំពូកទី ១០

## នីតិវិធីនៃការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

**ប្រការ ៣១ :**

ការកែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវសម្រេចដោយមហាសន្និបាត ។ ការលើកសំណើរ

កែប្រែលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទត្រូវធ្វើឡើង ដោយសមាជិកយ៉ាងតិចមួយភាគបី(១/៣)នៃសមា ជិកសហគមន៍នេសាទទាំងអស់ ហើយសំណើនេះត្រូវដាក់ជូនគណៈកម្មការសហគមន៍នេសាទមួយខែជាមុនបើកមហាសន្និបាត ។ លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងនេះ អាចកែប្រែបានលុះត្រាតែមានសំឡេងយល់ព្រមលើសពីពាក់កណ្តាល នៃសមាជិកមហា សន្និបាតសហគមន៍នេសាទ ។

## ជំពូកទី ១១

## អវសានប្បញ្ញត្តិ

**ប្រការ ៣២ :**

លក្ខន្តិកៈសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទលើកដំបូងនៅ ថ្ងៃទី ១៧ ខែ.សីហា ឆ្នាំ២០០៧ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខារបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។

ធ្វើនៅ ថ្ងៃទី ...17...... ខែ...08......ឆ្នាំ២០០៧

**ប្រធានគណៈកម្មការសហពន្ធ័សហគមន៍នេសាទ**

**បឹងត្រាំខ្នុម**

សេន _ ឡេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

| | |
|---|---|
| ឈ្មោះសហគមន៍នេសាទ | : ប្រាំងខ្ចុម |
| ភូមិ | : ច្បារអំពៅ ទួលចាន់ ស្ទឹងឆ្វេង តាងិល តាំងក្រាំង កំពង់ព្រះ មេសរ តោហ៊ៅ គងជ័យ |
| ឃុំ | : ច្បារអំពៅ ជាលា តាំងក្រាំង ព្រៃកកុយ |
| ស្រុក | : បាធាយ កងមាស |
| ខេត្ត | : កំពង់ចាម |

# បទបញ្ជាផ្ទៃក្នុងសហពន្ធ័សហគមន៍នេសាទបឹងគ្រាំងខ្ទុម

ដើម្បីធានាការគ្រប់គ្រងសហពន្ធ័សហគមន៍នេសាទឱ្យប្រព្រឹត្តទៅមានប្រសិទ្ធិភាព និងមានរបៀបរៀបរយល្អ សហពន្ធ័សហគមន៍នេសាទ វការពព្រាំសម្រេចដាក់ចេញបទបញ្ជាផ្ទៃក្នុងដូចខាងក្រោម ÷

**ប្រការ ១ :**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទគ្រប់រូបត្រូវមានការស្មោះត្រង់សាមគ្គីឯកភាពផ្ទៃក្នុងជួយស្ថាបនា ព្រមទាំងចូលរួមរៀនសូត្របច្ចេកទេសផ្សេងៗសម្រាប់បំរើឱ្យការរីកចំរើនរបស់សហគមន៍នេសាទ ។

**ប្រការ ២ :**

គណៈកម្មការ និងសមាជិកសហគមន៍នេសាទ ឬបុគ្គលណាដែលបានកេងប្រវ័ញ្ចធ្វើឱ្យខូចខាត ឬបាត់បង់ទ្រព្យសម្បត្តិ និងផលប្រយោជន៍សហគមន៍នេសាទ ត្រូវទទួលទណ្ឌកម្មដូចខាងក្រោមនេះ ÷

-ចំពោះសមាជិកសហគមន៍នេសាទ ឬ បុគ្គលដទៃទៀតត្រូវសង ឬ ទូទាត់ទៅតាមទំហំការខូចខាតជាក់ស្តែង តាមការសម្រេចរបស់អង្គប្រជុំគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីមិនព្រមសង ត្រូវដាក់ជូនមហាសន្និបាតសម្រេច ។

-ចំពោះគណៈកម្មការសហគមន៍នេសាទត្រូវសងឬទូទាត់សងការខូចខាតតាមការសម្រេចរបស់មហាសន្និបាត ។ ប្រសិនបើនិតិវិធីខាងលើនេះ នៅតែមិនអាចដោះស្រាយបាន គឺ ត្រូវអនុវត្តតាមផ្លូវច្បាប់ និង បទបញ្ជាជាធរមាន ។

**ប្រការ ៣ :**

សមាជិកសហគមន៍នេសាទគ្រប់រូប ត្រូវតែចូលរួមមហាសន្និបាតសហគមន៍នេសាទ និងរាល់កិច្ចប្រជុំ របស់សហគមន៍នេសាទ តាមការកោះអញ្ជើញរបស់ប្រធានគណៈកម្មការសហគមន៍នេសាទ ។ ក្នុងករណីដែលសមាជិកសហគមន៍ណាមិនបានមកចូលរួមប្រជុំចំនួន៣ដង ជាប់គ្នា ដោយគ្មានមូលហេតុច្បាស់លាស់ ត្រូវទទួលការណែនាំពីគណៈកម្មការសហគមន៍នេសាទ ។ ករណីនៅតែមិនរាងចាល គណៈកម្មការសហគមន៍ត្រូវធ្វើសំណើរទៅមហាសន្និបាតសម្រេចដើម្បីបញ្ឈប់ពីសមាជិកភាព ។

**ប្រការ ៤ :**

សិទ្ធិដាក់ទណ្ឌកម្ម ÷

**ក-ដោយគណៈកម្មការសហគមន៍នេសាទ**

-អប់រំណែនាំលើកទី១ លើកទី២ លើកទី៣

-ព្រមានផ្ទាល់មាត់ ឬ ជាលាយលក្ខណ៍អក្សរ

-ព្យួរសមាជិកភាពរបស់សមាជិកសហគមន៍នេសាទ

-បញ្ជូនបញ្ហាទំនាស់ទៅមហាសន្និបាតសម្រេច

-ផ្អាកការនេសាទ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅរដ្ឋបាលជលផល ចំពោះការធ្វើនេសាទលើស ទំហំ ចំនួន និងខុសប្រភេទ ពេលវេលា ទីតាំងតាមការកំណត់នៅក្នុងផែនការគ្រប់គ្រង និងកិច្ចព្រមព្រៀង នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ខ-មហាសន្និបាត ៖**

-អនុម័តការបណ្តេញចេញ ដូចមានចែងក្នុងប្រការ ៧ នៃលក្ខន្តិកៈសហគមន៍នេសាទ

-សម្រេចសំណងការខូចខាតលើទ្រព្យសម្បត្តិសហគមន៍នេសាទ

-សម្រេចដាក់ទណ្ឌកម្មដល់គណៈកម្មការ

-ដាក់ទណ្ឌកម្មដល់សមាជិក ឬ បុគ្គលដទៃដែលគណៈកម្មការមិនអាចដោះស្រាយបាន

**ប្រការ ៥ :**

សមាជិកសហគមន៍នេសាទគ្រប់រូបត្រូវរាយការណ៍ជូនគណៈកម្មការសហគមន៍នេសាទ អំពីសម្ភារៈ ឧបករណ៍នេសាទ ដែលគ្រួសារនិមួយៗ ប្រើប្រាស់នៅក្នុងកន្លែងនេសាទសហគមន៍ ។

**ប្រការ ៦ :**

សមាជិកសហគមន៍នេសាទ អាចប្រើប្រាស់ឧបករណ៍នេសាទជាលក្ខណៈគ្រួសារ នៅក្នុងរដូវបើកនេសាទដូចមានចែងខាងក្រោម ៖

-មងប្រវែង : ២០០ ម៉ែត្រ

-សំណាញ់ ទំហំមាត់ : ៦ ម៉ែត្រ

-ថ្នង ទំហំមាត់ : ២ ម៉ែត្រ

-លាន់ចំនួន : ៣០គ្រឿង

-លបចំនួន : ១០ គ្រឿង មុខបន្ទាត់ផ្ចិតប្រវែង ៥០សង្ទីម៉ែត្រ និងបណ្តោយប្រវែង ១ម៉ែត្រ

-សៃយឺនចំនួន : ៤ គ្រឿង មុខបន្ទាត់ផ្ចិតប្រវែង ៦០សង្ទីម៉ែត្រ និងបណ្តោយប្រវែង ១,២ម៉ែត្រ

-ប៉ោងចំនួន : ១០ គ្រឿង

-តុមចំនួន : ១០ គ្រឿង

-សន្ទូចរនង : ១០០ ផ្លែ

-សន្ទូចបង្កៃ : ៥០ ផ្លែ

-សន្ទូច : ផ្លែមួយ

**ប្រការ ៧ :**

សមាជិកសហគមន៍នេសាទ ដែល ÷

-ប្រព្រឹត្តផ្ទុយឬ រារាំងមិនអោយសមាជិកដ៏ទៃអនុវត្តសិទ្ធិ និងកាតព្វកិច្ចដូចក្នុងប្រការ ៥ នៃលក្ខន្តិក ត្រូវព្យួរសមាជិកភាពដោយគណៈកម្មការសហគមន៍នេសាទ ឬបណ្តេញចេញពីសមាជិកភាព ដោយមហាសន្និបាត

-មិនចូលរួមថែរក្សាការពារធនធានជលផល ឬ មិនរាយការណ៍អំពីសកម្មភាពបទល្មើសជលផល ត្រូវព្រមានដោយគណៈកម្មការសហគមន៍នេសាទ

-ប្រើប្រាស់ឧបករណ៍ហាមឃាត់ ធ្វើនេសាទខុសច្បាប់ ការកាប់ឆ្ការរានព្រៃលិចទឹកត្រូវទទួលការផ្តន្ទាទោសតាមច្បាប់ ស្តីពីជលផល ។

-ធ្វើនេសាទក្នុងកន្លែងអភិរក្សរបស់សហគមន៍នេសាទ ត្រូវផ្អាកការនេសាទ ហើយធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ទៅអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលជលផលមានសមត្ថកិច្ច

-អនុវត្តផ្ទុយពីបទប្បញ្ញត្តិច្បាប់ លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុង កិច្ចព្រមព្រៀង ឬផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ត្រូវផ្អាកការនេសាទ ទទួលការព្រមានជាលាយលក្ខណ៍អក្សរ ធ្វើកិច្ចសន្យាបញ្ឈប់ការនេសាទ និងរាយការណ៍ជាបន្ទាន់ជូនទៅសមត្ថកិច្ចជលផលដោះស្រាយតាមច្បាប់ ។

**ប្រការ ៨ :**

ចំពោះអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ អាចមានសិទ្ធិចេញ ចូល និងនេសាទក្នុងកន្លែងនេសាទសហគមន៍ ប៉ុន្តែត្រូវជូនព័ត៌មានដល់គណៈកម្មការសហគមន៍នេសាទ ហើយ ធ្វើកិច្ចសន្យា និងគោរពកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ លក្ខន្តិកៈបទបញ្ជាផ្ទៃក្នុង និងផែនការគ្រប់គ្រងកន្លែងនេសាទសហគមន៍ ។

ក្នុងករណីដែលអ្នកប្រើប្រាស់ធនធានជលផលដែលមិនមែនជាសមាជិកសហគមន៍នេសាទ មិនបាន គោរពតាមប្រការនេះ គណៈកម្មការសហគមន៍នេសាទមានសិទ្ធិបញ្ឈប់សកម្មភាពនេសាទរបស់ជននោះ ហើយធ្វើការអប់រំណែនាំ។

**ប្រការ ៩ :**

បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទនេះ ត្រូវបានអនុម័តដោយមហាសន្និបាតរបស់សហគមន៍នេសាទ លើកដំបូងនៅថ្ងៃទី ១៧ ខែសីហា ឆ្នាំ ២០០៨ និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខា ដោយគណៈកម្មការសហពន្ធ័សហគមន៍នេសាទ ។

ធ្វើនៅថ្ងៃទី...17....ខែ..08.......ឆ្នាំ ២០០៧

**ប្រធានគណៈកម្មការសហពន្ធ័សហគមន៍នេសាទ**

**បឹងប្រាំងខ្ពុម**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# សេចក្តីថ្លែងការណ៍
# នៃការបង្កើតសហគមន៍នេសាទ

| | | |
|---|---|---|
| ឈ្មោះសហគមន៍នេសាទ | : | ប្រាំងខ្ទុម |
| ភូមិ | : | ច្បារអំពៅ ទួលចាន់ ស្ទឹងឆ្វេង តាងិល តាំងក្រាំង កំពង់ព្រះ មេសរ គោហៅ គងជ័យ |
| ឃុំ | : | ច្បារអំពៅ ជាលា តាំងក្រាំង ព្រែកកុយ |
| ស្រុក | : | បាធាយ កងមាស |
| ខេត្ត | : | កំពង់ចាម |

# សេចក្តីថ្លែងការណ៍

សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទុម បានកកើត និងប្រារព្ធឡើងនៅថ្ងៃទី ១៧ ខែ. សីហា ឆ្នាំ២០០៧ ក្រោមការឧបត្ថម្ភគាំទ្រពីការិយាល័យអភិវឌ្ឍន៍សហគមន៍នេសាទ នៃរដ្ឋបាលជលផលសហការជាមួយខណ្ឌរដ្ឋបាលជលផលកំពង់ចាម បានជួយធ្វើការរៀបចំបង្កើត និងពង្រឹង ។

យើងខ្ញុំជាគណៈកម្មការសហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទុម សូមគោរព និងជំរាបជូនលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម មេត្តាជ្រាបថា ៖

ក្រោយពីការកែទំរង់វិស័យជលផលរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលបានកាត់ និងលុបផ្ទៃឡូត៍នេសាទមួយចំនួននៅក្នុងឆ្នាំ២០០១ ដើម្បីពង្រីកដែននេសាទជូនប្រជាពលរដ្ឋក្នុងការធ្វើនេសាទជាលក្ខណៈគ្រួសារសំរាប់ ផ្គត់ផ្គង់ជីវភាពរស់ និងកាត់បន្ថយភាពក្រីក្រក្នុងប្រទេស និងឱ្យមានការគ្រប់គ្រងដែននេសាទតាមរយៈបង្កើតជាសហគមន៍នេសាទ ។ ទន្ទឹមនឹងនោះ នៅក្នុងសហគមន៍យើងខ្ញុំ ដែននេសាទដែលរដ្ឋបានលុបចេញពីឡូត៍នេសាទ ក៏មានភាពអនាធិបតេយ្យក្នុងការនេសាទល្មើសច្បាប់ ដូចជាប្រើប្រាស់ឧបករណ៍ឆក់ ស្បៃមុង ដាក់សម្រះ និងការកាប់បំផ្លាញព្រៃលិចទឹក ធ្វើឱ្យធនធានជលផលមានភាពមហន្តរាយយ៉ាងធ្ងន់ធ្ងរ ។

ដើម្បីឆ្លើយតបទៅតាមគោលនយោបាយកែទំរង់វិស័យជលផលឆ្នាំ ២០០០ របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងអនុវត្តតាម អនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ របស់រាជរដ្ឋាភិបាលកម្ពុជា ឱ្យមានចូលរួមគ្រប់គ្រងក្នុងកិច្ចថែរក្សា ការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលនៅក្នុងសហគមន៍ឱ្យមាននិរន្តរភាព នៅឆ្នាំ២០០៧ ប្រជាពលរដ្ឋក្នុងសហគមន៍ បានមូលមតិគ្នាសុំបង្កើតជាសហគមន៍នេសាទ ហើយបានកកើត និងប្រារព្ធឡើងនៅថ្ងៃទី១៧ ខែ.សីហា ឆ្នាំ២០០៧ ។

## ១. លទ្ធផលនៃការរៀបចំបង្កើតសហគមន៍នេសាទ ៖

ដោយមានការសម្របសម្រួលពីមន្ត្រីជំនាញ និងអាជ្ញាធរមូលដ្ឋាន សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទុម បានចងក្រងឯកសារគ្រប់គ្រាន់សំរាប់ចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ជាមួយខណ្ឌរដ្ឋបាលជលផល កំពង់ចាម ដោយផ្អែកតាមជំពូកទី ៦ ក្នុងមាត្រាទី២៤ នៃអនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រង សហគមន៍នេសាទ របស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា រួមមាន ៖

-លក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់សហគមន៍នេសាទ

-បញ្ជីឈ្មោះគណៈកម្មការ និងសមាជិកសហគមន៍នេសាទ

-រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច គណៈកម្មការសហគមន៍នេសាទ

-ផែនទីកន្លែងនេសាទសហគមន៍

## ២. លទ្ធផលនៃការពង្រឹងសហគមន៍នេសាទ ៖

សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទុម ទទួលការណែនាំ និងចំណេះដឹងពីមន្ត្រីជលផល ដែលបានធ្វើការសម្របសម្រួលពង្រឹង រួមមាន ៖

-ផ្សព្វផ្សាយច្បាប់ ស្តីពី ជលផល និងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទ ដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងបណ្តុះបណ្តាលដល់គណៈកម្មការ និងក្រុមល្បាតសហគមន៍នេសាទ ។

-បណ្តុះបណ្តាលប្រកាសស្តីពីគោលការណ៍ណែនាំអំពីសហគមន៍នេសាទ

-បណ្តុះបណ្តាល ស្តីពីជំនាញការងារសម្របសម្រួល

-បណ្តុះបណ្តាល ស្តីពីការងារសរសេររបាយការណ៍ និងកំណត់ហេតុ

-បណ្តុះបណ្តាល ស្តីពីការងារគ្រប់គ្រងសហគមន៍

-ប្រជុំផ្តល់អនុសាស្ត្រលើការងារយាមល្បាត និងទប់ស្កាត់បទល្មើសនេសាទ

-ប្រជុំផ្តល់អនុសាស្ត្រលើការងារទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន និងសមត្ថកិច្ចជលផល ដើម្បីចូលរួមសហការ លើការងារគ្រប់គ្រង ថែរក្សា ការពារធនធានជលផល ។

-ជួយផ្តល់យោបល់ក្នុងការដោះស្រាយបញ្ហាដែលកើតមាននៅក្នុងសហគមន៍នេសាទ ។

**៣-លទ្ធផលនៃការគ្រប់គ្រងធនធានជលផលនៅក្នុងកន្លែងនេសាទសហគមន៍ :**

ដោយមានការគាំទ្រពីអាជ្ញាធរមូលដ្ឋាន សមត្ថកិច្ចជលផល និងមានការចូលរួមពីប្រជាពលរដ្ឋ សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម បានមានសកម្មភាពចុះអនុវត្តន៍ការងារគ្រប់គ្រងធនធានជលផល ដូចជា យាមល្បាតឃ្លាំមើលការធ្វើនេសាទល្មើសច្បាប់ ការកាប់ គាស់ ឈូស ឆាយ រាន ឆ្ការព្រៃលិចទឹក រាយការណ៍ជូនអាជ្ញាធរ មូលដ្ឋាន និងសមត្ថកិច្ចជលផល ដើម្បីមានវិធានការទប់ស្កាត់ បង្ក្រាប និងធ្វើការផ្សព្វផ្សាយបទដ្ឋាននានាដែលពាក់ព័ន្ធ នឹងសហគមន៍នេសាទ ដល់សមាជិកសហគមន៍ឱ្យបានជ្រាប។ សកម្មភាពនេះធ្វើឱ្យការធ្វើនេសាទល្មើសច្បាប់ និងការកាប់គាស់ ឈូសឆាយ រាន ឆ្ការព្រៃលិចទឹក ថយចុះមួយកំរិត ។

**៤-ការប្តេជ្ញាចិត្ត :**

យើងខ្ញុំគណៈកម្មការ សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម សូមធ្វើការប្តេជ្ញាចិត្ត និងសន្យាថា នឹងដឹកនាំការគ្រប់គ្រងធនធានជលផលក្នុងកន្លែងនេសាទសហគមន៍ អនុវត្តទៅតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ កិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ច្បាប់ស្តីពីជលផល និងលិខិតបទដ្ឋាននានា ដែលទាក់ទងទៅនឹងវិស័យជលផល និងអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចូលរួមកាត់បន្ថយភាពក្រីក្រ ។

យើងខ្ញុំសូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ នូវរាល់កំហុសឆ្គង នៃការអនុវត្តផ្ទុយពីបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងកិច្ចព្រមព្រៀង ។

សូមលោកនាយ មេត្តាទទួលនូវសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ពីយើងខ្ញុំ ។

ធ្វើនៅថ្ងៃទី.....11.......ខែ.....11........ឆ្នាំ២០០៩

**ប្រធានគណៈកម្មការសហពន្ធ័សហគមន៍**
**នេសាទបឹងប្រាំខ្ទម**

(signature)
សាន ស៊ុន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ឯកសារផ្សេងៗ

ឈ្មោះសហគមន៍នេសាទ : ប្រាំងខ្ទុម

ភូមិ : ច្បារអំពៅ ទួលចាន់ ស្ទឹងឆ្វេង តាងិល តាំងក្រាំង កំពង់ព្រះ មេសរ គោហ៊ើ គងជ័យ

ឃុំ : ច្បារអំពៅ ជាលា តាំងក្រាំង ព្រែកកុយ

ស្រុក : បាធាយ កងមាស

ខេត្ត : កំពង់ចាម

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ប្រធានគណៈកម្មការសហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម**
**សូមគោរពជូន**
**លោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម**

**កម្មវត្ថុ :** សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហពន្ធ័សហគមន៍បឹងប្រាំខ្ទម ។

**យោង :** -អនុក្រឹត្យ លេខ ២៥ អនក្រ.បក ចុះថ្ងៃទី ២០ ខែមិនា ឆ្នាំ២០០៧ ស្តីពីការគ្រប់គ្រងសហគមន៍នេសាទរបស់រាជរដ្ឋាភិបាលកម្ពុជា ។

-សេចក្តីសំរេចរបស់មហាសន្និបាតសហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម ដែលបានប្រារព្វឡើងនៅ ថ្ងៃទី១៧ ខែ សីហា ឆ្នាំ២០០៧ ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោកនាយខណ្ឌមេត្តាជ្រាបថា : ដោយផ្អែកតាមគោលនយោបាយកែទំរង់វិស័យជលផលក្នុងឆ្នាំ២០០០ របស់រាជរដ្ឋាភិបាលកម្ពុជា និងអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទ លេខ២៥អនក្រ.បកចុះថ្ងៃទី២០ ខែមិនា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាលកម្ពុជា សហពន្ធ័សហគមន៍បឹងប្រាំខ្ទម បានរៀបចំបង្កើតនៅដើមឆ្នាំ២០០៧ ដែលមានប្រជាពលរដ្ឋចូលរួម ចំនួនបួនសហគមន៍ គឺប្រជាពលរដ្ឋរស់នៅក្នុងឃុំច្បារអំពៅ ឃុំជាលា ឃុំតាំងក្រាំង ស្រុកបាធាយ និងឃុំព្រៃកកុយ ស្រុកកងមាស បានមូលមតិគ្នារៀបចំ និងប្រារព្វឡើងនៅ ថ្ងៃទី ១៧ ខែសីហា ឆ្នាំ២០០៧ ដោយមានមន្ត្រីខណ្ឌរដ្ឋបាលជលផលកំពង់ចាម សហការ ជាមួយមន្ត្រីរដ្ឋបាលជលផល អាជ្ញាធរមូលដ្ឋាន ជាអ្នកសម្របសម្រួល និងឧបត្ថម្ភគាំទ្រដោយគំរោងរដ្ឋបាលជលផល ។ ធ្វើឱ្យសហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម មានដំណើរការ ក្នុងការគ្រប់គ្រង ថែរក្សា ការពារ អភិរក្ស និងអភិវឌ្ឍន៍ធនធានជលផល និងបាន រៀបចំឯកសារពាក់ពន្ធ័ ក្នុងការចុះបញ្ជី ឈ្មោះសហគមន៍នេសាទគ្រប់គ្រាន់ទៅតាមប្រកាសលេខ ៣១៦ ប្រក.កសក ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៧ ស្តីពីគោលការណ៍ណែនាំ អំពីសហគមន៍នេសាទរបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ផងដែរ ។

ដើម្បីឱ្យមានកន្លែងនេសាទសំរាប់គ្រប់គ្រងច្បាស់លាស់ និងមានសិទ្ធិគ្រប់គ្រាន់ក្នុងការគ្រប់គ្រង ថែរក្សាការពារ អភិរក្ស អភិវឌ្ឍន៍ និងប្រើប្រាស់ធនធានជលផលមាននិរន្តរភាព និងឈានដល់ការចុះបញ្ជីឈ្មោះសហគមន៍នេសាទឱ្យមានការទទួលស្គាល់ជាផ្លូវការពីក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ សហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម សំណើសុំចុះកិច្ចព្រមព្រៀងកន្លែងនេសាទសហគមន៍ ជាមួយខណ្ឌរដ្ឋបាលជលផលកំពង់ចាម ។

**ជូនភ្ជាប់មកជាមួយនូវ :**

១-សេចក្តីថ្លែងការ នៃការបង្កើតសហពន្ធ័សហគមន៍នេសាទបឹងប្រាំខ្ទម

២-កិច្ចព្រមព្រៀងកន្លែងនេសាទសហពន្ធ័សហគមន៍បឹងប្រាំខ្ទម

៣-លក្ខន្តិកៈសហគមន៍នេសាទ

៤-បទបញ្ជាផ្ទៃក្នុងសហគមន៍នេសាទ

៥-បញ្ជីឈ្មោះគណៈកម្មការសហគមន៍នេសាទ

៦-រចនាសម្ព័ន្ធ តួនាទី និងភារកិច្ច គណៈកម្មការសហគមន៍

៧-បញ្ជីឈ្មោះសមាជិកសហគមន៍នេសាទ

៨-ផែនទីកន្លែងនេសាទ សហពន្ធ័សហគមន៍បឹងប្រាំខ្ទម

អាស្រ័យដូចបានជំរាបជូន និងសំណើខាងលើ សូមលោកនាយខណ្ឌរដ្ឋបាលជលផលកំពង់ចាម មេត្តាពិនិត្យ និងសំរេចដោយក្តីអនុគ្រោះ ។

ធ្វើនៅថ្ងៃទី...11....ខែ...11.....ឆ្នាំ២០០៩...

**ប្រធានគណៈកម្មការសហព័ន្ធសហគមន៍**

**នេសាទបឹងប្រាំខ្ទម**

ទិនា .ឡិន